# **របាយការណ៍ស្តីពីការជួញដូរមនុស្ស**

ចេញផ្សាយដោយការិយាល័យតាមដាននិងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

ថ្ងៃទី ១២ ខែ  មិថុនា ឆ្នាំ ២០០៧

**លិខិតរបស់លោកស្រីរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក Condoleezza Rice**

ជូនមិត្តអ្នកអាន:

កាលពីពីររយឆ្នាំមុន សភាប្រទេសអង់គ្លេសបានដាក់អោយនៅក្រៅច្បាប់នូវជំនួញទាសករឆ្លងកាត់មហាសមុទ្រអាត្លង់ទិច បន្ទាប់ពីមានការតស៊ូរាប់ទសវត្ស ដែលដឹកនាំដោយលោក William Wiberforce ។

ការជួញដូរមនុស្សគឺជាទំរង់សម័យទំនើបនៃទាសភាព ជាប្រភេទថ្មីនៃពាណិជ្ជកម្មទាសករសាកលលោក ។ អ្នកប្រព្រឹត្តសំលឹងឃើញអ្នកទន់ខ្សោយបំផុតក្នុងចំណោមពួកយើង ពិសេសស្ត្រីនិងកុមារ ដើម្បីការចំណេញរបស់គេ ។ គេល្បួងជនរងគ្រោះអោយធ្លាក់ទៅក្នុងទាសភាពដោយការបង្ខំនិងទាសភាពផ្លូវភេទ ។ សព្វថ្ងៃនេះ ជាថ្មីម្តងទៀត មនសិការរបស់យើងបានសុំអោយយើងបញ្ចប់ការបញ្ចុះតំលៃមនុស្សប្រុសស្រី ដែលសុទ្ធតែជាមនុស្សដូចយើងដែរ ។ ដូចកាលពីសតវត្សទី ១៩ អ្នកតស៊ូលុបបំបាត់(ទាសភាព)ដែលមានការប្តេជ្ញាចិត្តនៅជុំវិញពិភពលោកបានប្រមូលផ្តុំគ្នាជាចលនាសាកលលោកមួយ ដើម្បីតតាំងនឹងបទឧក្រិដ្ឋដែលគួរអោយស្អប់ខ្ពើមនេះ ។ លោកប្រធានាធិបតី George W. Bush បានប្តេជ្ញាចិត្តដឹកនាំសហរដ្ឋអាមេរិកក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាក្នុងសតវត្សទី ២១ ដ៏ធ្ងន់ធ្ងរនេះ ហើយប្រជាជាតិទាំងអស់ដែលមានការប្តេជ្ញាចិត្តក្នុងការបញ្ចប់ការជួញដូរមនុស្ស គឺជាដៃគូរបស់សហរដ្ឋអាមេរិកដែលមានការតាំងចិត្តយ៉ាងខ្លាំង ។

*របាយការណ៍ស្តីពីការជួញដូរមនុស្ស*ប្រចាំឆ្នាំលើកទី ៧ ចងក្រងការខិតខំរបស់រដ្ឋាភិបាលបរទេសក្នុងការទប់ស្កាត់ការជួញដូរមនុស្ស កាត់ទោសជនល្មើស និងការពារជនរងគ្រោះ ។ របាយការណ៏ស្រាវជ្រាវដល់កន្លែងខ្មៅងងឹតបំផុត ដោយចុចចំៗនូវប្រទេសទាំងឡាយ មិនថាជាប្រទេសមិត្តឬសត្រូវឡើយ ដែលមិនបានបំពេញអោយបានគ្រប់គ្រាន់ ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ។

អំណាចនៃភាពអៀនខ្មាស់បានជំរុញអោយប្រទេសជាច្រើនធ្វើសកម្មភាព និងនាំដល់ការកែទំរង់ដែលមិនធ្លាប់មានពីមុនមក ហើយការយល់ដឹងកាន់តែច្រើន បាននាំដល់ភាពជឿនលឿនជាដុំកំភួនដល់ការប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋនេះ និងជួយជនរងគ្រោះតាមកន្លែងដែលគេបានរកឃើញ ។

ការផ្ចាញ់ការជួញដូរមនុស្សគឺជាការអំពាវនាវផ្នែកសីលធម៌ដ៏ធំមួយនាសម័យយើងសព្វថ្ងៃនេះ ។ រួមជាមួយសម្ព័ន្ធមិត្តនិងមិត្តរបស់យើង យើងនឹងបន្តការប្រឹងប្រែងរបស់យើងដើម្បីបញ្ចប់អំពើដ៏យង់ឃ្នងនេះ ។ សូមអរគុណដែលបានចូលរួមក្នុងចលនាលុបបំបាត់ឧក្រិដ្ឋកម្មថ្មីនេះ ។ ការរួមគ្នាធ្វើអោយយើងសំរេចបាននូវផ្លែផ្កា ហើយការរួមគ្នាធ្វើអោយយើងអាចកសាងនូវពិភពលោកមួយ ដែលកាន់តែមានវិបុលភាព សេរីភាពនិងសុវត្ថិភាពសំរាប់មនុស្សគ្រប់រូប ។

ដោយការគោរពដោយស្មោះ

Condoleezza Rice

## សេចក្តីផ្តើម

ការឆ្លើយរបស់ជនរងគ្រោះដែលចុះក្នុងរបាយការណ៍ គ្រាន់តែដើម្បីរៀបរាប់បង្ហាញតែប៉ុណ្ណោះ ហើយមិនមែនមានគ្រប់ទំរង់នៃការជួញដូរដែលមានមកនោះទេ ។ រឿងទាំងនេះអាចកើតមាននៅគ្រប់កន្លែងនៃពិភពលោក ហើយត្រូវបានលើកឡើងដើម្បីពន្យល់បង្ហាញពីទំរង់ជាច្រើននៃការជួញដូរ និងកន្លែងនានាជាច្រើនដែលវាកើតមាន ។ គ្មានប្រទេសណាថាមិនមាននោះទេ ។ ឈ្មោះជនរងគ្រោះទាំងអស់ក្នុងរបាយការណ៍នេះមិនមែនជាឈ្មោះពិតទេ ។ រូបថតនៅលើគំរបក្រៅនៃរបាយការណ៍និងរូបថតភាគច្រើនដែលគ្មានសរសេរអ្វីនៅលើ ក្នុងរបាយការណ៍នេះ មិនមែនជារូបថតពិតនៃជនគ្រោះដោយការជួញដូរទេ គឺគ្រាន់តែផ្តល់មកដើម្បីបង្ហាញ ទំរង់ផ្សេងៗជាច្រើននៃការកេងប្រវ័ញ្ច ដែលអាចកំណត់ន័យនៃការជួញដូរនិងនានាភាពនៃវប្បធម៌ដែលគេរក ឃើញជនរងគ្រោះនៅក្នុងនោះ ។

*ប្រទេសភូមា: ទាហានកុមារឈ្មោះ Ko Aung បាននិយាយថា "គេបានចាប់បង្ខំខ្ញុំអោយចូលធ្វើទាហាន ។ ល្ងាចមួយ នៅពេលខ្ញុំកំពុងតែមើលវីដេអូក្នុងភូមិខ្ញុំ ទាហានបីនាក់បានមកដល់ ។ គេសួររកអត្តសញ្ញាណប័ណ្ណ ហើយសួរថាតើយើងចង់ចូលបំរើកងទ័ពដែរទេ ។ យើងបានពន្យល់ថា យើងមិនទាន់គ្រប់អាយុទេហើយមិនមានអត្តសញ្ញាណប័ណ្ណទេ ។ ខ្ញុំបាននិយាយថាទេ ហើយត្រឡប់មកផ្ទះវិញនៅល្ងាចនោះ តែនៅព្រឹកបន្ទាប់ មានអង្គភាពជ្រើសរើសទាហានបានមកដល់ភូមិរបស់ខ្ញុំ ហើយទាមទារអោយមនុស្សពីរនាក់ចូលបំរើទ័ព ។ គេបាននិយាយថាអ្នកដែលមិនមានលុយបង់ចំនួន ៣ 000 kyats (៩ ដុល្លា) ត្រូវចូលបំរើទ័ព ។ ឪពុកម្តាយខ្ញុំមិនមានលុយបង់ ហើយពួកយើងទាំង ១៩ នាក់ត្រូវបានគេកេណ្ឌនិងបញ្ជូនទៅកាន់មជ្ឈមណ្ឌលហ្វឹកហ្វឺនកងទ័ព ។*

## បំណង

ច្បាប់តំរូវអោយក្រសួងការបរទេសសហរដ្ឋអាមេរិកផ្ញើរបាយការណ៍រាល់ឆ្នាំទៅសភាសហរដ្ឋអាមេរិក ស្តីពីការប្រឹងប្រែងរបស់រដ្ឋាភិបាលបរទេសក្នុងការលុបបំបាត់ទំរង់ធ្ងន់ធ្ងរនៃការជួញដូរមនុស្ស ។ នេះគឺជារបាយការណ៍ប្រចាំឆ្នាំលើកទី ៧ ស្តីពីការជួញដូរមនុស្ស ។ របាយការណ៍នេះមានបំណងលើកកំពស់ការយល់ដឹងនៅទូទាំងសាកលលោក សង្កត់ធ្ងន់លើការប្រឹងប្រែងរបស់សហគមន៍អន្តរជាតិ និងលើកទឹកចិត្តរដ្ឋាភិបាលបរទេសអោយចាត់វិធានការប្រកបដោយប្រសិទ្ធិភាពប្រឆាំងនឹងគ្រប់ទំរង់ទាំងអស់នៃការជួញដូរមនុស្ស ។

ច្បាប់អាមេរិកស្តីពីការងារប្រឆាំងនឹងការជួញដូរមនុស្ស (TVPA) ឆ្នាំ ២000 ដែលត្រូវបានធ្វើវិសោធនកម្ម កំណត់ថា បំណងនៃការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សគឺដើម្បីដាក់ទណ្ឌកម្មដល់អ្នកប្រព្រឹត្ត ការពារជនរងគ្រោះ និងការពារកុំអោយការជួញដូរកើតមានឡើង ។ ការរំដោះមនុស្សចេញពីការជាប់ក្នុងស្ថានភាពដូចទាសករគឺជាបំណងធំបំផុតរបស់របាយការណ៍នេះនិងរបស់គោលនយោបាយប្រឆាំងការជួញដូរមនុស្សនៃរដ្ឋាភិបាលសហរដ្ឋអាមេរិក

ការជួញដូរមនុស្សគឺជាការគំរាមកំហែងដែលមានលក្ខណៈច្រើនយ៉ាង ។ វាបំបាត់សិទ្ធិនិងសេរីភាពរបស់ជនរងគ្រោះ វាបង្កើនគ្រោះថ្នាក់ដល់សុខភាពមនុស្ស ហើយវាជុតបញ្ឆេះការរីកដាលនៃឧក្រិដ្ឋកម្មដែលមានការចាត់តាំង ។

ការជួញដូរមនុស្សមានផលប៉ះពាល់ធ្ងន់ធ្ងរលើជនរងគ្រោះម្នាក់ៗ ដែលច្រើនតែទទួលរងនូវការរំលោភលើរូបរាងកាយនិងផ្លូវចិត្ត ការរំលោភផ្លូវភេទ ការគំរាមកំហែងលើខ្លួនគេនិងគ្រួសាររបស់គេ ការលួចឯកសារ និងមានរហូតដល់ស្លាប់ខ្លួន ។ តែផលប៉ះពាល់នៃការជួញដូរមនុស្សមានលើសពីជនរងគ្រោះម្នាក់ៗទៅទៀត ។ វាប៉ះពាល់សុខភាព សុវត្ថិភាពនិងសន្តិសុខរបស់ប្រជាជាតិទាំងមូល ។

មានប្រទេសកាន់តែច្រើនហើយដែលកំពុងតែខិតខំខ្លាំងក្នុងការលុបបំបាត់បទឧក្រិដ្ឋដែលគួរអោយស្អប់ខ្ពើមនេះ ។ ប្រទេសមួយដែលមិនបានខិតខំជាដុំកំភួនក្នុងការគោរពតាមបទដ្ឋានអប្បបរិមា ក្នុងការលុបបំបាត់ការជួញដូរមនុស្ស ដូចដែលមានចែងក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្ស TVPA  ទទួលការអោយតំលៃ "លំដាប់ថ្នាក់ទី ៣" ក្នុងរបាយការណ៏នេះ ។ ការវាយតំលៃនេះអាចធ្វើអោយសហរដ្ឋអាមេរិកបញ្ឈប់ការផ្តល់ជំនួយបរទេសដែលមិនទាក់ទងពាណិជ្ជកម្មនិងមនុស្សធម៌ ។ ក្នុងការវាយតំលៃការប្រឹងប្រែងរបស់រដ្ឋាភិបាលបរទេស របាយការណ៏នេះសង្កត់ធ្ងន់លើ ការនាំយកមកកាត់ទោស ការការពារនិងការការពារកុំអោយកើតមាន ។ យុទ្ធសាស្ត្រដែលផ្តោតជាសំខាន់លើជនងគ្រោះដោយការជួញដូរ ទាមទារអោយយើងគិតគូរពីការជួយសង្គ្រោះ ការស្តារកាយសម្បទារ និងសមាហរណកម្មឡើងវិញ និងទាមទារអោយយើងលើកទឹកចិត្តដល់ការរៀនសូត្រនិងការចែករំលែកការប្រតិបត្តិល្អៗក្នុងផ្នែកទាំងនេះ ។

ឆ្នាំនេះគឺជាខួបលើកទី ២00 នៃការបំបាត់ជំនួញទាសករឆ្លងសមុទ្រអាត្លង់ទិច ។ ចលនាដែលដឹកនាំដោយសមាជិកសភាអង់គ្លេសម្នាក់ឈ្មោះ William Wilberforce ត្រូវការពេលរាប់ទសវត្សទើបទទួលបានជោគជ័យ ។ វាតំរូវអោយប្រជាជាតិមួយកំណត់អោយបានស៊ីជំរៅនិងធ្វើអោយមានលក្ខណៈទូលំទូលាយនូវនិយមន័យស្តីពីសេចក្តីថ្លៃថ្នូររបស់មនុស្ស ។ វាតំរូវអោយប្រជាជាតិមួយប្រកាសថា គុណតំលៃផ្នែកសីលធម៌មានទំងន់ធ្ងន់ជាងផលប្រយោជន៏ផ្នែកពាណិជ្ជកម្ម ។ សព្វថ្ងៃនេះ គ្រប់ប្រជាជាតិត្រូវតែប្រកាន់តាមគោលការណ៏នេះអោយបាន ក្នុងការងារលុបបំបាត់ការជួញដូរមនុស្ស ដែលជាទំរង់មួយនៃទាសភាពសម័យទំនើប ។

***កម្ពុជាៈការជួញដូរកុមារដើម្បីបំរើផ្លូវភេទ*** *បងប្អូនស្រីពីរនាក់ គីណា រ៉ែននិង សិទ្ធីដែលមានអាយុ ១០ និង ១២ ឆ្នាំបានរស់នៅក្នុងក្រុងភ្នំពេញ ។ ឪពុកម្តាយរបស់គេបានយល់ព្រមបញ្ជូនកុមារីទាំងពីរនេះទៅអោយផ្ទះមួយដែលជួលដោយជនជាតិអាឡឺម៉ង់ម្នាក់ ដើម្បីបំរើផ្លូវភេទជាថ្នូរនឹងលុយ ។ នៅក្នុងផ្ទះនោះ បុរសជនជាតិអាឡឺម៉ង់នោះបានរំលោភផ្លូវភេទលើកុមារទាំងពីរហើយថតវីដេអូនៃសកម្មភាពរំលោភនោះ ។ ដោយអ្នករស់នៅក្បែរខាងម្នាក់បានលួចផ្តល់ពត៌មាន អង្គការមិនមែនរដ្ឋាភិបាលក៏បានទៅរំដោះយកក្មេងស្រីទាំងពីរនាក់នោះមកវិញ ។ ក្មេងទាំងពីរនាក់នោះបានឆ្លើយដាក់ទោសលើបុរសនោះនិងឪពុកម្តាយរបស់គេ ។*

**និយមន័យស្តីពីការជួញដូរមនុស្ស**

*U.S. Embassy, #1, Street 96, Watphnom; Phone: 023-728-258; Fax: 023-728-800; Email: chreav@state.gov*

ច្បាប់ប្រឆាំងនឹងការជួញដូរមនុស្សនិងការពារជនរងគ្រោះ (TVPA) កំណត់ "ទំរង់ធ្ងន់ធ្ងរនៃការជួញដូរ" ថា:

**ក. ការជួញដូរផ្លូវភេទដែលក្នុងនោះ ការប្រព្រឹត្តផ្លូវភេទតាមលក្ខណៈជួញដូរ ត្រូវបានធ្វើឡើងក្រោមការបង្ខំ ការបន្លំ ឬដែលក្នុងនោះ មនុស្សដែលត្រូវបានជំរុញអោយប្រព្រឹត្តអំពើនេះ មិនទាន់មានអាយុដល់ ១៨ ឆ្នាំទេ ។ ឬ ខ. ការជ្រើសរើស លាក់ទុក ដឹកនាំ ការផ្តល់ឬការទទួលមនុស្សសំរាប់អោយធ្វើពលកម្មឬផ្តល់សេវា តាមរយៈការប្រើ កំលាំង ការបន្លំ ឬការបង្ខំចិត្ត ដើម្បីអោយជនរងគ្រោះបង្ខំចិត្តផ្តល់ការបំរើ ធ្វើជាខ្ញុំបំរើ ការដាក់អោយជាប់ បំណុលដោះមិនរួច ឬទាសភាព ។**

ជនរងគ្រោះមិនចាំបាច់ត្រូវបានគេដឹកជញ្ជូនពីកន្លែងមួយទៅកន្លែងមួយ ទើបបទល្មើសនេះត្រូវនឹងនិយមន័យនេះទេ ។

***ប្រទេសឥណ្ឌា:ពលកម្មដោយការបង្ខិតបង្ខំ*** *នៅពេល Aakesh មានអាយុ ៥ ឆ្នាំ វាលេងជាមួយមិត្តភក្តិវានៅក្នុងភូមិ ស្រាប់តែមានមនុស្សប្រុសបើកបរយាន្តមកក្នុងភូមិរបស់វាហើយសួរទៅក្មេងៗថា តើវាចង់មើល "វីដេអូ" ទេ ។ ក្មេងប្រុសៗទាំងនោះលោតឡើងគូទឡាន ហើយឡាននោះក៏បើកចេញទៅចំងាយ ២០០ ម៉ៃល៍ ។ ក្មេងប្រុសទាំងនោះត្រូវបានគេចាក់សោរដាក់ក្នុងបន្ទប់ចោលរាប់ថ្ងៃ ដោយមិនមានផ្តល់អ្វីអោយបរិភោគព្រមទាំងត្រូវរងការវាយដំផង ។ ក្មេងទាំងនោះត្រូវបានគេចាប់ទុកអស់រយៈពេល ៩ ឆ្នាំ ។ មិត្តរបស់ Aakesh ពីរនាក់បានស្លាប់ ដោយម្នាក់ត្រូវបានគេបាញ់ស្លាប់នៅពេលប៉ុនប៉ងគេចខ្លួន និងម្នាក់ទៀតបានស្លាប់ដោយសារមានជំងឺដែលមិនត្រូវបានគេព្យាបាល ។ ក្មេងទាំងនោះមានអាយុ ១៤ ឆ្នាំ នៅពេលត្រូវបានរំដោះ ។ ពួកគេស្ទើរតែនិយាយមិនចេញ ។ ពួកគេហូបមិនគ្រប់គ្រាន់ ហើយមានរបួស តែទីបំផុត មានសេរីភាពឡើងវិញ ។*

**ទំហំនិងលក្ខណៈនៃទាសភាពសម័យទំនើប (The Scope and Nature of Modern-Day Slavery)**

ចរិកលក្ខណៈរួមនៃការជួញដូរមនុស្សគឺការប្រើកំលាំង ការបន្លំ ឬការបង្ខិតបង្ខំ ដើម្បីកេងប្រវ័ញ្ចយកចំណេញលើមនុស្សម្នាក់ ។ ជនរងគ្រោះអាចត្រូវបានគេកេងប្រវ័ញ្ចពលកម្ម កេងប្រវ័ញ្ចផ្លូវភេទ ឬកេងប្រវ័ញ្ចទាំងពីរបែបនេះ ។ ការកេងប្រវ័ញ្ចពលកម្មរួមមានទាសភាព ការបង្ខំអោយធ្វើពលកម្ម ការធ្វើអោយជាប់បំណុលដោះមិនរួច ។ ការកេងប្រវ័ញ្ចផ្លូវភេទតាមធម្មតាមានការរំលោភក្នុងឧស្សាហកម្មជួញដូរផ្លូវភេទ ។ ក្នុងករណីផ្សេងទៀត ជនរងគ្រោះត្រូវបានគេកេងប្រវ័ញ្ចនៅតាមផ្ទះរបស់មនុស្សដែលតំរូវអោយជនរងគ្រោះរួមភេទជាមួយផងធ្វើការអោយផង ។ ការប្រើកំលាំងឬការបង្ខិតបង្ខំអាចមានលក្ខណៈដោយផ្ទាល់ និងប្រកបដោយហឹង្សាឬមានជាលក្ខណៈចិត្តសាស្ត្រ ។

មានការវាយតំលៃជាច្រើនលើទំហំនៃទាសភាពសម័យទំនើប ។ អង្គការពលកម្មអន្តរជាតិ (ILO) ដែលជាទីភ្នាក់ងាររបស់សហប្រជាជាតិទទួលបន្ទុកលើបទដ្ឋានពលកម្ម ការងារនិងបញ្ហាការពារផ្នែកសង្គម បានធ្វើការប៉ាន់ប្រមាណថា មានមនុស្ស ១២,៣ លាននាក់ដែលត្រូវបានគេបង្ខំអោយធ្វើពលកម្មធ្ងន់ ជាប់ជាទាសករពលកម្មបង្ខំអោយធ្វើពលកម្មទាំងនៅជាកុមារ និងជាទាសករកាមគុណ ។ ក្នុងការប៉ាន់ប្រមាណដទៃទៀតមានពី ៤ លានទៅ ២៧ លាននាក់ ។

គិតក្នុងមួយឆ្នាំៗ បើយោលតាមការស្រាវជ្រាវដែលឧបត្ថម្ភដោយរដ្ឋាភិបាលសហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០៦ មានមនុស្សប្រហែល ៨ សែននាក់ត្រូវបានគេជួញដូរឆ្លងកាត់ព្រំដែនប្រទេស ។ ចំនួននេះមិន រាប់បញ្ចូលមនុស្សរាប់លាននាក់ដែលត្រូវបានជួញដូរក្នុងប្រទេសរបស់គេផងទេ ។ ប្រហែល ៨០% នៃជនរងគ្រោះដោយការជួញដូរឆ្លងកាត់ព្រំដែនគឺជាស្ត្រីនិងកុមារី ហើយមានរហូតដល់ ៥០% គឺជាកុមារមិនទាន់គ្រប់អាយុ ។ ភាគច្រើននៃជនរងគ្រោះដោយការជួញដូរឆ្លងកាត់ព្រំដែនគឺជាស្ត្រី ដែលត្រូវរងការកេងប្រវ័ញ្ចផ្លូវភេទ ។ ចំនួននេះមិនរាប់បញ្ចូលមនុស្សប្រុសស្រីរាប់លាននាក់ នៅជុំវិញពិភពលោកដែលត្រូវបានគេជួញដូរក្នុងប្រទេសរបស់គេ ដែលភាគច្រើនគឺដើម្បីបង្ខំអោយធ្វើពលកម្ម ដូចទាសករ ។

អ្នកជួញដូរមនុស្សសំលឹងរកមើលជនដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ។ គោលដៅរបស់គេច្រើនតែកុមារនិងនារីក្មេងៗ ហើយល្បិចកលរបស់គេមានលក្ខណៈថ្មីៗហើយពិសពុល ដោយមានបំណងទាក់ បង្ខិតបង្ខំ និងធ្វើអោយជនរងគ្រោះឆាប់ទុកចិត្ត ។ ល្បិចកលទាំងនោះច្រើនមានដូចជាការសន្យារៀបការដើម្បីអោយគេមានជីវិតរស់នៅប្រសើរ ការផ្តល់ការងារធ្វើ ឬឱកាសទទួលបានការសិក្សា ។

សញ្ជាតិនៃជនរងគ្រោះដោយការជួញដូរមានផ្សេងៗដូចវប្បធម៌របស់ពិភពលោកដែរ ។ អ្នកខ្លះចេញពីប្រទេសកំពុងអភិវឌ្ឍ ដើម្បីចង់អោយជីវភាពរស់នៅរបស់គេបានប្រសើរឡើង តាមរយៈការងារដែលទាមទារជំនាញទាបៗនៅក្នុងប្រទេសដែលជឿនលឿនជាង ។ អ្នកខ្លះទៀតធ្លាក់ខ្លួនចូលទៅក្នុងពលកម្មដោយការបង្ខំឬដូចទាសករ ក្នុងប្រទេសរបស់ខ្លួនឯង ។ ស្ត្រីដែលចង់មានអនាគតល្អ ច្រើនជឿការសន្យាថាមានការងារធ្វើនៅបរទេស ជាអ្នកមើលក្មេង ជាអ្នកបំរើតាមផ្ទះ ជាអ្នករត់តុ ឬអ្នកបង្ហាញម៉ូដ ពោលគឺការងារដែលជនប្រព្រឹត្តការជួញដូរប្រែក្លាយអោយទៅជាពេស្យាចារដែលគ្មានច្រកចេញបាន ។ គ្រួសារខ្លះបន្ទុកបណ្តាក់កូនអោយមនុស្សធំ ដែលច្រើនជាបងប្អូន ដែលសន្យាថានឹងផ្តល់ឱកាសបានរៀនសូត្រ តែបែរជាលក់ក្មេងទាំងនោះអោយធ្លាក់ក្នុងស្ថានភាពរងការកេងប្រវ័ញ្ចទៅវិញ ។

**ចំណុចផ្តោតសំខាន់នៃរបាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ ២០០៧**

របាយការណ៍ជួញដូរមនុស្សគឺជារបាយការណ៍ដែលមានលក្ខណៈពេញលេញជាងគេ ទូទាំងពិភពលោក ស្តីពីការប្រឹងប្រែងរបស់រដ្ឋាភិបាលនានាក្នុងការប្រយុទ្ធប្រឆាំងនឹងទំរង់ធ្ងន់ធ្ងរនៃការជួញដូរមនុស្ស ។ របាយការណ៍នេះ សំរាប់រយៈពេលពីខែមេសា ឆ្នាំ ២០០៦ ដល់ខែមិនា ឆ្នាំ ២០០៧ ។ របាយការណ៍មាននិយាយពីប្រទេសដែលត្រូវបានកំណត់ថាជាប្រទេសប្រភព ប្រទេសឆ្លងកាត់បប្រទេស្សគោលដៅ នៃជនរងគ្រោះក្នុងចំនួនច្រើន ដោយការជួញដូរក្នុងទំរង់ធ្ងន់ធ្ងរ ។ របាយការណ៍ជួញដូរមនុស្សឆ្នាំ ២០០៧ នេះ ពិនិត្យជារួមលើស្ថានភាពថ្មីៗនិងទំហំនៃទាសភាពសម័យទំនើបនិងសកម្មភាពជាច្រើនរបស់រដ្ឋាភិបាលនៅជុំវិញពិភពលោក ក្នុងការប្រឈមនិងលុបបំបាត់ការជួញដូរមនុស្ស ។

ពីព្រោះថាការជួញដូរមនុស្សទំនងជារាលដាលដល់គ្រប់ប្រទេសនៅក្នុងពិភពលោក ការលុបចោលនូវប្រទេសមួយចេញពីរបាយការណ៍គ្រាន់តែជាការបង្ហាញកង្វះពតិមានគ្រប់គ្រាន់តែប៉ុណ្ណោះ ។ សេចក្តីអធិប្បាយពីប្រទេសមួយៗរៀបរាប់ពីទំហំនិងលក្ខណៈនៃបញ្ហាជួញដូរ ហេតុផលនៃការបញ្ចូលប្រទេសទៅក្នុងរបាយការណ៍

និងការប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ ។ សេចក្តីរៀបរាប់និមួយៗមានការវាយតំលៃផងដែរពីការគោរពតាមរបស់រដ្ឋាភិបាលលើបទដ្ឋានអប្បបរិមាក្នុងការលុបបំបាត់ការជួញដូរ ដូចមានចែងក្នុងច្បាប់ TVPA និងមានបញ្ចូលសេចក្តីស្នើជាយោបល់សំរាប់សកម្មភាពបន្ថែមក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ ។ ផ្នែកដទៃទៀតនៃសេចក្តីរៀបរាប់ពីប្រទេសមួយៗរៀបរាប់ពីការខិតខំរបស់រដ្ឋាភិបាលមួយៗក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរ ការពារជនរងគ្រោះ និងការពារកុំអោយមានការជួញដូរ ។ សេចក្តីរៀបរាប់មួយៗពន្យល់មូលដ្ឋានសំរាប់កំណត់លំដាប់វាយតំលៃប្រទេសមួយថា ស្ថិតនៅក្នុងលំដាប់ទី ១ ទី ២ បញ្ជីតាមដានលំដាប់ទី ២ ឬ លំដាប់ទី ៣ ។ បើប្រទេសមួយស្ថិតក្នុងបញ្ជីតាមដានលំដាប់ទី ២ សេចក្តីរៀបរាប់មានសេចក្តីពន្យល់តាមលក្ខណៈវិនិច្ឆ័យដែលមានក្នុងច្បាប់ TVPA ។

ច្បាប់ TVPA កំណត់កត្តាចំនួនបីដែលត្រូវពិចារណាក្នុងការកំណត់ថាតើប្រទេសមួយគួរស្ថិតក្នុងលំដាប់ ទី ២ (ឬបញ្ជីតាមដានលំដាប់ទី ២) ឬលំដាប់ទី ៣ ។ កត្តាទី ១: កំរិតនៃប្រទេសមួយជាប្រទេសប្រភព ឆ្លងកាត់ ឬប្រទេសគោលដៅសំរាប់ទំរង់ធ្ងន់ធ្ងរនៃការជួញដូរ ។ កត្តាទី ២: កំរិតដែលរដ្ឋាភិបាលនៃប្រទេសមួយមិនបានគោរពតាមបទដ្ឋានអប្បបរិមារបស់ច្បាប់ TVPA ដែលមានរួមបញ្ចូលជាពិសេសគឺកំរិតនៃអំពើពុករលួយទាក់ទងនឹងការជួញដូរមនុស្ស ។ កត្តាទី ៣: ធនធាននិងសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការដោះស្រាយនិងលុបបំបាត់ទំរង់ធ្ងន់ធ្ងរនៃការជួញដូរមនុស្ស ។

ប្រទេសខ្លះបានរៀបចំសន្និសីទនិងបានបង្កើតក្រុមកាងារពិសេសឬផែនការសកម្មភាពជាតិ ដើម្បីកំណត់ទិដៅនៃការងារប្រឆាំងការជួញដូរ ។ ប៉ុន្តែ មានតែសន្និសីទ ផែនការនិងក្រុមការងារពិសេសមិនមានទំងន់ទេក្នុងការវាយតំលៃការប្រឹងប្រែងរបស់ប្រទេសមួយ ។ ផ្ទុយទៅវិញ របាយការណ៍នេះផ្តោតលើសកម្មភាពជាក់ស្តែងដែលរដ្ឋាភិបាលប្រកាន់យកក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ ពិសេសការនាំខ្លួនយកមកកាត់ទោសនិងការដាក់អោយជាប់ពន្ធនាគារនូវជនប្រព្រឹត្តការជួញដូរ វិធានការការពារជនរងគ្រោះ និងការខិតខំកុំអោយមានការជួញដូរកើតមានឡើង ។ របាយការណ៍មិនផ្តល់ទំងន់ដល់ច្បាប់ដែលស្ថិតក្នុងពង្រាងនៅឡើយ ឬច្បាប់ដែលមិនទាន់ត្រូវបានអនុម័ត ។ ជាចំណុចចុងក្រោយ របាយការណ៍នេះមិនផ្តោតការយកចិត្តទុកដាក់លើការប្រឹងប្រែងរបស់រដ្ឋាភិបាលដែលរួមចំណែកដោយមិនផ្ទាល់ដល់ការកាត់បន្ថយការជួញដូរ ដូចជាកម្មវិធីអប់រំ ការជួយធ្វើអោយមានការអភិវឌ្ឍន៍សេដ្ឋកិច្ច ឬកម្មវិធីលើកកំពស់សមភាពជេនឌ័រឡើយ បើទោះបីជាទាំងអស់នេះជាការងារដែលគេគួរធ្វើក្តី ។

***ប្រទេសរ្វ៉ាន់ដា/ចក្រភពអង់គ្លេស: ការជួញដូរផ្លូវភេទ*** *នៅពេលនាងមានអាយុ ១៤ ឆ្នាំ ចៅហ្វាយនាយរបស់ Adnita ដែលជាអ្នកជំនួញម្នាក់ដែលនាងធ្វើការអោយនៅផ្សារទីក្រុង Kigali បានប្រាប់អោយនាងទៅជាមួយបុរសពីរនាក់ ។ គាត់និយាយថាពួកគេនឹងនាំនាងទៅរស់នៅបរទេស ដែលនៅទីនោះ នាងនឹងមានសុវត្ថិភាពហើយអាចទៅរៀនបាន ។ នៅពេលនាងទៅដល់ប្រទេសអង់គ្លេស មានបុរសម្នាក់មកយកនាងពីព្រលានយន្តហោះ ហើយនាំនាងទៅកាន់ផ្ទះមួយ ។ បុរសម្នាក់ទៀតមកជួបនាងហើយរំលោភនាង ។ អស់រយៈពេល ២ ឆ្នាំ នាងត្រូវ*

*បានគេចាក់សោរអោយនៅតែក្នុងផ្ទះបាយ ដែលមានតែបន្ទប់ទឹកនិងអាងទឹក ។ ពួកគេបានទុកនាងជាទាសករផ្លូវភេទ រហូតដល់នាងរត់គេចចេញ ហៅឡានគេជិះ ហើយអ្នកបើកបាននាំនាងទៅជួបនគរបាល*

## វិធីសាស្ត្រ

ក្រសួងការបរទេសសហរដ្ឋអាមេរិកបានរៀបចំរបាយការណ៍នេះ ដោយប្រើពតិមានដែលបានមកពីបណ្តាស្ថានទូតអាមេរិក មន្ត្រីរដ្ឋាភិបាលបរទេស អង្គការមិនមែនរដ្ឋាភិបាលនិងអង្គការអន្តរជាតិ របាយការណ៍ដែលត្រូវបានបោះពុម្ពផ្សាយ ការធ្វើដំណើរដើម្បីធ្វើការស្រាវជ្រាវទៅកាន់គ្រប់តំបន់ និងពតិមានដែលផ្ញើមកកាន់ tipreport@state.gov ។ អ៊ីម៉េលនេះត្រូវបានបង្កើតឡើងសំរាប់អង្គការមិនមែនរដ្ឋាភិបាលនិងបុគ្គលធ្វើការចែករំលែកពតិមានស្តីពីភាពជឿនលឿនរបស់រដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាជួញដូរមនុស្ស ។ ស្ថានទូតសហរដ្ឋអាមេរិកបានរាយការណ៍ពីស្ថានភាពជួញដូរមនុស្សនិងសកម្មភាពរបស់រដ្ឋាភិបាល ដោយផ្អែកលើការស្រាវជ្រាវយ៉ាងជិតដល់ ដែលរួមមានទាំងការប្រជុំជាមួយមន្ត្រីរដ្ឋាភិបាល តំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ មន្ត្រីនៃអង្គការអន្តរជាតិ អ្នកសារពតិមាន អ្នកជំនាញនិងអ្នកបានរួចខ្លួនមកវិញ ។ ដើម្បីចងក្រងឯកសារសំរាប់ឆ្នាំនេះ ក្រសួងការបរទេសបានពិនិត្យលើប្រភពពតិមានថ្មីៗ ស្តីពីប្រទេសមួយៗ ដើម្បីធ្វើការវាយតំលៃ ។ ការវាយតំលៃការខិតខំរបស់រដ្ឋាភិបាលនិមួយៗប្រឆាំងនឹងការជួញដូរមនុស្ស គឺជាដំណើរការដែលមានពីរជំហ៊ាន ។

## ជំហ៊ានទី ១: រកមើលជនរងគ្រោះអោយបានច្រើន

ដំបូង ក្រសួងការបរទេសសហរដ្ឋអាមេរិកកំណត់ថាតើប្រទេសមួយជាប្រទេស "ប្រភព ឆ្លងកាត់ឬជាប្រទេសគោលដៅ សំរាប់ជនរងគ្រោះច្រើនពីទំរង់ធ្ងន់ធ្ងរនៃការជួញដូរមនុស្ស" ដែរឬទេ ដែលជាទូទៅរាប់ពី ១០០ នាក់ឡើងទៅ គឺដូចគ្នានឹងចំនួនកំណត់ក្នុងរបាយការណ៍មុនៗដែរ ។ ចំពោះប្រទេសខ្លះ ដែលគេមិនអាចប្រមូលពតិមានបែបនេះបាន មិនត្រូវបានកំណត់លំដាប់ទេ តែត្រូវបានដាក់ទៅក្នុងផ្នែកករណីពិសេស ពីព្រោះមានសញ្ញាបង្ហាញពីការជួញដូរ ។

## ជំហ៊ានទី ២: ការកំណត់លំដាប់

ក្រសួងការបរទេសសហរដ្ឋអាមេរិកដាក់ប្រទេសនិមួយៗដែលមានឈ្មោះក្នុងរបាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ ២០០៧ ទៅក្នុងបញ្ជីណាមួយនៃបញ្ជីទាំងបី ដែលក្នុងនោះត្រូវបានហៅថាលំដាប់ តាមការកំណត់របស់ច្បាប់ TVPA ។ ការដាក់លំដាប់នេះផ្អែកច្រើនលើកំរិតសកម្មភាពរបស់រដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ ជាជាងផ្អែកលើទំហំនៃបញ្ហា បើទោះបីបញ្ហានោះសំខាន់យ៉ាងណាក៏ដោយ ។ ដំបូងក្រសួងការបរទេសសហរដ្ឋអាមេរិកវាយតំលៃថាតើរដ្ឋាភិបាលមួយគោរពបានពេញលេញតាមបទដ្ឋានអប្បបរិមារបស់ច្បាប់ TVPA សំរាប់ការលុបបំបាត់ការជួញដូរ ( មានលំអិតនៅត្រង់ទំព័រ ២២៨-២២៩) ដែរឬទេ ។ រដ្ឋាភិបាលដែលគោរពតាមបានពេញលេញ ត្រូវបានដាក់អោយស្ថិតនៅក្នុងលំដាប់ថ្នាក់លេខ ១ ។ ចំពោះរដ្ឋាភិបាលដទៃទៀត ក្រសួងការបរ

ទេសសហរដ្ឋអាមេរិកពិចារណាមើលថាតើ រដ្ឋាភិបាលទាំងនោះកំពុងតែខិតខំច្រើនគួរសម ដើម្បីគោរពតាមដែរឬទេ ។ រដ្ឋាភិបាលដែលកំពុងខិតខំច្រើនគួរសមក្នុងការគោរពតាមបទដ្ឋានអប្បបរិមានេះ ត្រូវបានដាក់អោយស្ថិតក្នុងលំដាប់លេខ ២ ។ ។ ប្រទេសដែលត្រូវបានវាយតំលៃថា មិនគោរពតាមបទដ្ឋានអប្បបរិមាហើយ ក៏មិនខិតខំច្រើនដើម្បីបំពេញតាមបទដ្ឋានអប្បបរិមានេះ ត្រូវបានចាត់ចូលក្នុងលំដាប់ថ្នាក់ទី ៣ ។ មួយទៀត គឺលក្ខណៈវិនិច្ឆ័យលើបញ្ជីតាមដានពិសេសត្រូវបានយកមកពិចារណា ហើយបើឃើញថាសមស្រប ប្រទេសដែលស្ថិតក្នុងលំដាប់ទី ២ ត្រូវបានដាក់អោយស្ថិតក្នុងបញ្ជីតាមដានលំដាប់ទី ២ ។

**បញ្ជីតាមដានពិសេស — បញ្ជីតាមដានលំដាប់ទី ២** (The Special Watch List – Tier 2 Watch List)

ច្បាប់ TVPA បានបង្កើត "បញ្ជីតាមដានពិសេស" នៃប្រទេសក្នុងរបាយការណ៍ជួញដូរ ដែលគួរទទួលការពិនិត្យជាពិសេស ។ ក្នុងបញ្ជីនេះមាន ១) ប្រទេសស្ថិតក្នុងលំដាប់ទី ១ ក្នុងរបាយការណ៍នៅពេលនេះ តែស្ថិតក្នុងលំដាប់ទី ២ ក្នុងរបាយការណ៍ឆ្នាំ ២០០៦ ។ ២) ប្រទេសដែលពេលនេះស្ថិតក្នុងលំដាប់ទី ២ តែក្នុងរបាយការណ៍ឆ្នាំ ២០០៦ ស្ថិតក្នុងលំដាប់ទី ៣ ។ ៣) ប្រទេសដែលស្ថិតក្នុងលំដាប់ទី ២ ក្នុងរបាយការណ៍ពេលនេះ ដោយសារប្រទេសនោះមានលក្ខណៈដូចខាងក្រោមនេះ ។

**ក) ចំនួនជនរងគ្រោះដោយការជួញដូរក្នុងទំរង់ធ្ងន់ធ្ងរមានច្រើនគួរអោយកត់សំគាល់ឬកំពុងតែមានកំណើនគួរអោយកត់សំគាល់ ។**

**ខ) មិនឃើញមានភស្តុតាងដែលបង្ហាញថាប្រទេសនោះកំពុងតែបង្កើនការប្រឹងប្រែង ក្នុងការប្រយុទ្ធប្រឆាំងនឹងទំរង់ធ្ងន់ធ្ងរនៃការជួញដូរមនុស្ស គិតពីឆ្នាំកន្លងទៅ ដែលរួមមានការបង្កើនការស៊ើបអង្កេត ការកាត់ទោសចំពោះបទល្មើសដោយការជួញដូរ កំណើននៃជំនួយចំពោះជនរងគ្រោះ និងការឃើញមានភស្តុតាងកាន់តែតិចស្តីពីការពាក់ព័ន្ធក្នុងការទំរង់ធ្ងន់ធ្ងរនៃការជួញដូរដោយមន្ត្រីរដ្ឋាភិបាល ឬ**

**គ) ការកំណត់ឃើញថារបស់ប្រទេសមួយកំពុងតែខិតខំច្រើនគួរអោយកត់សំគាល់ដើម្បីគោរពតាមបទដ្ឋានអប្បបរិមា ដោយផ្អែកតាមការប្តេជ្ញាចិត្តរបស់ប្រទេសនោះក្នុងការប្រកាន់ជំហានបន្ថែមទៀតនៅឆ្នាំក្រោយ ។**

ចំណាត់ប្រភេទទី ៣ នេះ (ដែលមាន ក ខ និង គ) ត្រូវបានកំណត់ដោយក្រសួងការបរទេសសហរដ្ឋអាមេរិកថាជា "បញ្ជីតាមដានលំដាប់ទី ២" ។ ក្នុងរបាយការណ៍ដែលចេញនៅខែមិថុនា ឆ្នាំ ២០០៦ មានប្រទេសចំនួន ៣២ ត្រូវបានដាក់ក្នុងបញ្ជីតាមដានលំដាប់ទី ២ ។ រួមជាមួយប្រទេសចំនួន ២ ដែលត្រូវបានវាយតំលៃឡើងវិញអោយស្ថិតក្នុងបញ្ជីតាមដានលំដាប់ទី ២ ក្នុងខែកញ្ញា ឆ្នាំ ២០០៦ និងប្រទេសចំនួន ៥ ដែលបំពេញបានតាមលក្ខខ័ណ្ឌក្នុងចំណាត់ក្រុមពីរដំបូងខាងលើ (ឡើងមួយលំដាប់ពីរបាយការណ៍ឆ្នាំ ២០០៥ ទៅរបាយការណ៍ឆ្នាំ ២០០៦ ស្តីពីការជួញដូរ) ប្រទេសទាំង ៣៩ នេះត្រូវបានដាក់បញ្ចូលក្នុង "ការវាយតំលៃបណ្តោះអាសន្ន" ដែលត្រូវបានបញ្ចេញដោយក្រសួងការបរទេសសហរដ្ឋអាមេរិក នៅថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០០៧ ។

ក្នុងចំណោមប្រទេសចំនួន ៣៨ ដែលស្ថិតក្នុងបញ្ជីតាមដានលំដាប់ទី ២ ក្នុងអំឡុងពេលនៃការវាយតំលៃបណ្តោះអាសន្ន មាន ១០ ប្រទេសបានឡើងមកលំដាប់ទី ២ ក្នុងរបាយការណ៍នេះ ចំណែក ៧ ប្រទេសទៀតបាន

ធ្លាក់ទៅលំដាប់ទី ៣ ហើយ ១៧ ប្រទេសនៅក្នុងបញ្ជីតាមដានលំដាប់ទី ២ ដដែល ។ ប្រទេសដែលស្ថិតក្នុងបញ្ជីតាមដានពិសេសក្នុងរបាយការណ៍នេះ នឹងត្រូវបានពិនិត្យឡើងវិញ ក្នុងសេចក្តីវាយតំលៃបណ្តោះអាសន្ន ដែលត្រូវផ្ញើជូនទៅសភាសហរដ្ឋអាមេរិក ត្រឹមថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០០៨ ។

**ទណ្ឌកម្មដែលអាចមានសំរាប់ប្រទេសក្នុងលំដាប់ទី ៣**

រដ្ឋាភិបាលនៃប្រទេសដែលស្ថិតក្នុងលំដាប់ទី ៣ អាចរងនូវការដាក់ទណ្ឌកម្មខ្លះ ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកអាចបញ្ឈប់ជំនួយបរទេសដែលមិនមានការទាក់ទងនឹងពាណិជ្ជកម្ម ឬមិនទាក់ទងនឹងមនុស្សធម៌ ។ ប្រទេសដែលមិនអាចទទួលជំនួយបែបនេះ លែងទទួលបានថវិកាសំរាប់ការចូលរួមដោយមន្ត្រីនិងនិយោជិករបស់រដ្ឋាភិបាលនោះ ក្នុងកម្មវិធីផ្លាស់ប្តូរផ្នែកវប្បធម៌និងការអប់រំ ។ ស្របតាមច្បាប់ TVPA រដ្ឋាភិបាលដែលទទួលទណ្ឌកម្មបែបនេះថែមទាំងរងនូវការប្រឆាំងពីសហរដ្ឋអាមេរិកក្នុងការទទួលបានជំនួយ (លើកលែងតែជំនួយខ្លះទាក់ទងនឹងការអភិវឌ្ឍន៍ ពាណិជ្ជកម្មនិងមនុស្សធម៌) ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជាអង្គការរូបិយប័ណ្ណអន្តរជាតិ (IMF) និងធនាគារពិភពលោក ។ ទណ្ឌកម្មនឹងចាប់មានសុពលភាពនៅថ្ងៃទី ១ ខែតុលា ឆ្នាំ ២០០៧ បើសិនជាមានដាក់ ។

ទណ្ឌកម្មមួយផ្នែកឬទាំងអស់តាមច្បាប់ TVPA អាចត្រូវបានលើកលែងវិញ បើសិនជាប្រធានាធិបតីកំណត់ឃើញថា ការផ្តល់ជំនួយបែបនេះដល់រដ្ឋាភិបាលនឹងជំរុញដល់បំណងរបស់ច្បាប់ ឬម្យ៉ាងទៀត បើវាបំរើផលប្រយោជន៍ជាតិរបស់សហរដ្ឋអាមេរិក ។ ច្បាប់ TVPA ក៏បានចែងផងដែរថា ទណ្ឌកម្មអាចនឹងលើកលែងវិញ បើសិនជាចាំបាច់ ដើម្បីជៀសវាងផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រជាជនដែលងាយរងគ្រោះ រួមទាំងស្ត្រីនិងកុមារ ។ គេមិនអាចដាក់ទណ្ឌកម្មបានទេ បើសិនជាប្រធានាធិបតីយល់ឃើញថា ក្រោយពីការចេញរបាយការណ៍នេះនិងមុនពេលដែលទណ្ឌកម្មត្រូវបានកំណត់ រដ្ឋាភិបាលបានគោរពតាមបទដ្ឋានអប្បបរិមា ឬក៏កំពុងតែខិតខំជាដុំកំភួន ដើម្បីគោរពតាម ។

ដោយមិនគិតពីលំដាប់ទី គ្រប់ប្រទេសអាចធ្វើការខិតខំថែមទៀត រួមទាំងសហរដ្ឋអាមេរិកផងដែរ ។ លំដាប់សំរាប់ប្រទេសនិមួយៗមិនមែននៅជាអចិន្ត្រៃយ៍ទេ ។ ប្រទេសទាំងអស់ត្រូវតែរក្សានិងបង្កើនការខិតខំក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ។

**តើរបាយការណ៍ត្រូវបានប្រើយ៉ាងដូចម្តេច?**

របាយការណ៍នេះគឺជាឧបករណ៍ផ្នែកការទូត ដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកប្រើដើម្បីធ្វើជាមធ្យោបាយសំរាប់ការពិភាក្សានិងការលើកទឹកចិត្តជាបន្ត និងជាគោលណែនាំសំរាប់ជួយផ្តោតធនធានលើគោលនយោបាយនិងកម្មវិធីស្តីពីការដាក់ទោស ការការពារជនរងគ្រោះនិងការការពារកុំអោយមានការជួញដូរកើតឡើង ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងបន្តទាក់ទងជាមួយរដ្ឋាភិបាលនានាស្តីពីខ្លឹមសារនៃរបាយការណ៍ជួញដូរ ដើម្បីពង្រឹងកិច្ចខិតខំរួមគ្នា ក្នុងការលុបបំបាត់ការជួញដូរ ។ ក្នុងឆ្នាំខាងមុខនេះ និងជាពិសេស ក្នុងពេលប៉ុន្មានខែមុនពេលមានការសំរេចទាក់ទងនឹងទណ្ឌកម្មប្រឆាំងនឹងប្រទេសដែលស្ថិតក្នុងលំដាប់ទី ៣ ក្រសួងការបរទេសអាមេរិកនឹងប្រើពត៌មានដែលបានប្រមូលនៅពេលនេះ ដើម្បីកំណត់ទិសដៅជំនួយអោយមានប្រសិទ្ធិភាពច្រើន និងធ្វើការ

ជាមួយប្រទេសដែលត្រូវការការជួយក្នុងការប្រយុទ្ធនឹងការជួញដូរមនុស្ស ។ ក្រសួងការបរទេសអាមេរិកសង្ឃឹមថា របាយការណ៍នេះនឹងជំរុញបន្ថែមដល់ការប្រឹងប្រែងរបស់រដ្ឋាភិបាលនិងផ្នែកមិនមែនរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនៅជុំវិញពិភពលោក ។

***ប្រទេសកូរេខាងជើង/ប្រទេសចិនៈការរៀបការដោយបង្ខំ*** Hanuel *បាននិយាយថា "ខ្ញុំត្រូវបានលក់អោយធ្វើជាប្រពន្ធរបស់បុរសជនជាតិចិនអាយុ ៤៧ ឆ្នាំម្នាក់ ដែលគ្មានជំនាញការងារនិងមានជំងឺធ្ងន់ផង ។ ប្តីរបស់ខ្ញុំតែងតែវាយខ្ញុំហើយនិយាយថា "តើឯងដឹងទេថាអញបានចំណាយលុយប៉ុន្មានលើរូបឯង?" ខ្ញុំមិនមែនជានារីកូរេខាងជើងតែម្នាក់ឯងទេ នៅតំបន់នេះ ។ នៅពេលខ្ញុំនិយាយជាមួយនារីកូរេខាងជើងឯទៀត យើងចាប់ដឹងខ្លួនថាពួកយើងត្រូវបានគេលក់ខ្លួនអោយរៀបរការបែបនេះ" ។*

***នីសេរីយ៉ា/សហរដ្ឋអាមេរិកៈ*** *កុមារីឈ្មោះ* Jenny *បានចាកចេញពីប្រទេសនីសេរីយ៉ាដែលជាប្រទេសកំណើតរបស់នាង មកកាន់សហរដ្ឋអាមេរិក ដើម្បីធ្វើការក្នុងផ្ទះអោយគ្រួសារមួយ ដែលជាអ្នកមកពីប្រទេសអាហ្វ្រិកដូចនាងដែរ ។ នាងគិតថា គេនឹងបង់លុយអោយនាងថ្លៃមើលកូនរបស់គេ តែការពិតមិនអញ្ចឹងទេ ។ អស់រយៈពេល ៥ ឆ្នាំ ថៅកែប្រុសរំលោភផ្លូវភេទលើរូបនាងជាញឹកញាប់ហើយថៅកែស្រីវាយដំនាង ដោយពេលខ្លះដោយប្រើដំបងនិងមានពេលមួយនោះ ដោយប្រើស្បែកជើងកែងចោទផង ។ ដោយទទួលបានពតិមាននេះពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ មន្ត្រីអនុវត្តច្បាប់ក៏បានទៅរំដោះនាងហើយនាំជនល្មើសទៅកាត់ទោស ។*

**និយមន័យនៃ "ការជួញដូរមនុស្ស"**

ច្បាប់ស្តីពីការការពារជនរងគ្រោះដោយការជួញដូរកំណត់និយមន័យនៃការជួញដូរមនុស្សថាជាៈ
(ក) ការជួញដូរផ្លូវភេទដែលក្នុងនោះអំពើរកផលចំណេញពីផ្លូវភេទត្រូវបានធ្វើតាមរយៈការបង្ខំ បោកប្រាស ឬ ដែលក្នុងនោះ មនុស្សដែលត្រូវបានគេនាំអោយរួមភេទបែបនេះ មិនទាន់គ្រប់អាយុ ១៨ ឆ្នាំនៅឡើយ ។ ឬ
(ខ) ការជ្រើសរើស ការលាក់ទុក ការដឹកនាំ ការផ្តល់ឬការទទួលអោយធ្វើពលកម្មឬបំរើសេវា តាមរយៈការប្រើកំលាំង ការបោកប្រាសឬការបង្ខិតបង្ខំ ដើម្បីអោយអ្នកនោះសុខចិត្តទ្រាំទទួលយកទាសភាព ភាពជាកម្មករដាច់ថ្លៃឬភាពដូចជាទាសករគេដោយសារបំណុលដែលដោះមិនរួច ។

**និយមន័យរបស់ពាក្យ**

*ការជួញដូរផ្លូវភេទ* មានន័យថាការដើរជ្រើសរើស លាក់ទុក ដឹកជញ្ជូន ការផ្តល់ ឬការទទួលមនុស្ស អោយប្រព្រឹត្តសកម្មភាពផ្លូវភេទ ក្នុងន័យធ្វើអាជីវកម្ម (Commercial sex act) ។

*ការប្រព្រឹត្តសកម្មភាពផ្លូវភេទក្នុងន័យធ្វើអាជីវកម្ម* មានន័យថាសកម្មភាពផ្លូវភេទ ដែលក្នុងនោះអ្វីដែលមានតំលៃត្រូវបានផ្តល់ឬទទួល ។

*ការបង្ខិតបង្ខំ (Coercion)* (ក) ការគំរាមកំហែងថានឹងធ្វើបាបធ្ងន់ធ្ងរឬការចាប់ឃុំឃាំង ។ (ខ) គំរោងផែនការ ឬ ទំរង់បែបផែនណាមួយដែលចង់អោយគេជឿថា ការខកខានមិនបានធ្វើតាមអំពើអ្វីមួយនឹងនាំទៅដល់ការឈឺចាប់ធ្ងន់ធ្ងរឬការឃុំឃាំងខ្លួនប្រាណ ។ (គ) ការរំលោភឬការគំរាមថានឹងរំលោភដំណើរការច្បាប់ ។

*ការចាប់អោយបំរើដូចជាទាសករ (Involuntary Servitude)* មានលក្ខខ័ណ្ឌនៃការបំរើដូចជាទាសករដោយ (ក) គំរោង ផែនការ ឬទំរង់បែបផែន ដែលមានបំណងធ្វើអោយគេជឿថា បើអ្នកនោះមិនព្រមទទួលយកលក្ខខ័ណ្ឌ ឬ មិនព្រមបន្តទទួលលក្ខខ័ណ្ឌបែបនេះ នោះជននោះនឹងត្រូវទទួលរងការឈឺចាប់ធ្ងន់ធ្ងរ ឬត្រូវស្ថិតនៅក្រោមការឃុំឃាំងលើរាងកាយ ឬ (ខ) ការរំលោភឬការគំរាមថានឹងរំលោភដំណើរការច្បាប់ ។

## ការកំណត់លំដាប់ថ្នាក់

| លំដាប់ថ្នាក់ទី ១ | | | |
|---|---|---|---|
| AUSTRALIA | FINLAND | KOREA, REP. OF | NORWAY |
| AUSTRIA | FRANCE | LITHUANIA | POLAND |
| BELGIUM | GEORGIA | LUXEMBOURG | SLOVENIA |
| CANADA | GERMANY | MALAWI | SPAIN |
| COLOMBIA | HONG KONG | MOROCCO | SWEDEN |
| CZECH REPUBLIC | HUNGARY | THE NETHERLANDS | SWITZERLAND |
| DENMARK | ITALY | NEW ZEALAND | UNITED KINGDOM |

| លំដាប់ថ្នាក់ទី ២ | | | |
|---|---|---|---|
| AFGHANISTAN | ECUADOR | MACEDONIA | SENEGAL |
| ALBANIA | EL SALVADOR | MADAGASCAR | SERBIA |
| ANGOLA | ESTONIA | MALI | SIERRA LEONE |
| AZERBAIJAN | ETHIOPIA | MALTA | SINGAPORE |
| BANGLADESH | GABON | MAURITIUS | SLOVAK REPUBLIC |
| BELIZE | GHANA | MONGOLIA | SURINAME |
| BENIN | GREECE | MONTENEGRO | TAIWAN |
| BOLIVIA | GUINEA | NEPAL | TAJIKISTAN |
| BOSNIA/HERZEGOVINA | GUINEA-BISSAU | NICARAGUA | TANZANIA |
| BRAZIL | INDONESIA | NIGER | THAILAND |

| | | | |
|---|---|---|---|
| BULGARIA | ISRAEL | NIGERIA | TOGO |
| BURKINA FASO | JAMAICA | PAKISTAN | TURKEY |
| CAMEROON | JAPAN | PANAMA | UGANDA |
| CHILE | JORDAN | PARAGUAY | URUGUAY |
| CONGO (DRC) | KYRGYZ REPUBLIC | PERU | VIETNAM |
| COSTA RICA | LAOS | PHILIPPINES | YEMEN |
| COTE D'IVOIRE | LATVIA | PORTUGAL | ZAMBIA |
| CROATIA | LEBANON | ROMANIA | ZIMBABWE |
| EAST | TIMOR | LIBERIA | RWANDA |

| បញ្ជីតាមដានលំដាប់ថ្នាក់ទី ២ | | | |
|---|---|---|---|
| ARGENTINA | CYPRUS | HONDURAS | MOLDOVA |
| ARMENIA | DJIBOUTI | INDIA | MOZAMBIQUE |
| BELARUS | DOMINICAN REP. | KAZAKHSTAN | PAPUA NEW GUINEA |
| BURUNDI | EGYPT | KENYA | RUSSIA |
| CAMBODIA | FIJI | LIBYA | SOUTH AFRICA |
| CENTRAL AFRICAN REP. | THE GAMBIA | MACAU | SRI LANKA |
| CHAD | GUATEMALA | MAURITANIA | UKRAINE |
| CHINA (PRC) | GUYANA | MEXICO | UNITED ARAB EMIRATES |

| លំដាប់ថ្នាក់ទី ៣ | | | |
|---|---|---|---|
| ALGERIA | EQUATORIAL GUINEA | NORTH KOREA | SUDAN |
| BAHRAIN | IRAN | OMAN | SYRIA |
| BURMA | KUWAIT | QATAR | UZBEKISTAN |
| CUBA | MALAYSIA | SAUDI ARABIA | VENEZUELA |

## សេចក្តីអធិប្បាយស្តីពីប្រទេសកម្ពុជា – (បញ្ជីតាមដានលំដាប់ទី ២)

កម្ពុជាគឺជាប្រទេសប្រភព ប្រទេសឆ្លងកាត់និងជាប្រទេសគោលដៅសំរាប់បុរស នារី និង កុមារ ដែលត្រូវបានគេជួញដូរដើម្បីការកេងប្រវ័ញ្ចផ្លូវភេទ និងការបង្ខំអោយធ្វើពលកម្ម ។ ស្ត្រីនិងកុមារកម្ពុជាត្រូវបានគេជួញដូរទៅប្រទេសថៃនិងប្រទេសម៉ាឡេស៊ី ដើម្បីការកេងប្រវ័ញ្ចផ្លូវភេទនិងការចាប់បង្ខំអោយធ្វើពលកម្មតាមរោងចក្រនិងធ្វើជាខ្ញុំបំរើនៅតាមផ្ទះ ។ ចំណែកបុរសកម្ពុជាវិញត្រូវបានគេជួញដូរអោយធ្វើពលកម្មដោយបង្ខំក្នុងផ្នែកកសិកម្ម នេសាទនិងសំណង់ ក្នុងប្រទេសទាំងនេះ ។ កុមារកម្ពុជាត្រូវបានជួញដូរទៅប្រទេសវៀតណាមនិងប្រទេសថៃអោយដើរសុំទាន ។ កម្ពុជាគឺជាប្រទេសឆ្លងកាត់និងជាប្រទេសគោលដៅសំរាប់ការជួញដូរកុមារនិងស្ត្រីចិននិងវៀតណាម ដើម្បីកេងប្រវ័ញ្ចផ្លូវភេទ ។ ការជួញដូរផ្លូវភេទលើកុមារនិងនារីក៏កើតមានក្នុងរង្វង់ព្រំដែនកម្ពុជាផងដែរពីតំបន់ជនបទមកទីក្រុង ដូចជាក្រុងភ្នំពេញ សៀមរាបនិងក្រុងព្រះសីហនុ ។

រដ្ឋាភិបាលកម្ពុជាមិនគោរពបានពេញលេញតាមបទដ្ឋានអប្បបរិមា សំរាប់ការបំបាត់ការជួញដូរទេ ។ យ៉ាងណាក្តី ក៏រដ្ឋាភិបាលកំពុងតែខិតខំច្រើនគួរសមក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរនេះ ។ ប្រទេសកម្ពុជាស្ថិតក្នុងបញ្ជីតាមដានលំដាប់ទី ២ អស់រយៈពេល ២ ឆ្នាំជាប់គ្នាមកហើយ ពីព្រោះខ្លួនមិនបានបង្ហាញភស្តុតាងថាបានបង្កើនការខិតខំដើម្បីប្រឆាំងនឹងការជួញដូរមនុស្ស ពិសេសក្នុងបញ្ហាទាក់ទងនឹងរបាយការណ៍ថាមានមន្ត្រីសាធារណៈពាក់ព័ន្ធក្នុងការជួញដូរនេះ ។ ទោះបីជា មន្ត្រីថ្នាក់ខ្ពស់ក្នុងរដ្ឋាភិបាលមានការតាំងចិត្តក្នុងការងារប្រឆាំង នឹងការជួញដូរក្តី តែរបាយការណ៍ស្តីពីការចូលដៃ របស់មន្ត្រីសាធារណៈបានធ្វើអោយជោគជ័យរបស់រដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមានកំរិតព្រំ ដែន ។ លើសពីនេះទៀត រដ្ឋាភិបាលបានខកខាតមិនបានអនុម័តច្បាប់ប្រឆាំងនឹងការជួញដូរដែលមានលក្ខណៈគ្រប់ ជ្រុងជ្រោយនិងចាំបាច់ជាខ្លាំង ។ ច្បាប់នេះនៅតែស្ថិតក្នុងពង្រាងនៅឡើយអស់រយៈពេល ៧ ឆ្នាំមកហើយ ។ កម្ពុជាគួរតែអនុម័តច្បាប់ពេញលេញប្រឆាំងនឹងការជួញដូរនិងបង្កើនការខិតខំថែមទៀតដើម្បីនាំខ្លួនមកជំនុំជំរះទោសនូវមន្ត្រីដែលទទួលផលឬមានការពាក់ព័ន្ធនឹងការជួញដូរ ។

**ការនាំខ្លួនមកកាត់ទោស**

រដ្ឋាភិបាលកម្ពុជាមានភាពជឿនលឿនតិចតួចក្នុងការងារអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរមនុស្សរបស់ខ្លួន ។ កម្ពុជាហាមប្រាមទំរង់នៃការជួញដូរភាគច្រើន តែមិនមែនទាំងអស់ទេ តាមរយៈច្បាប់ឆ្នាំ ១៩៩៦ របស់ខ្លួនស្តីពីការបង្ក្រាបការចាប់ជំរិត ការជួញដូរនិងកេងប្រវ័ញ្ចមនុស្សនិងច្បាប់ការងារឆ្នាំ ១៩៩៧ របស់ខ្លួន ដែលមាននិយាយដល់អន្ទាក់បំណុល ទាសភាព និងការបង្ខំអោយកុមារធ្វើពលកម្ម ។ ទណ្ឌកម្មចំពោះការជួញដូរដើម្បីអាជីវកម្មផ្លូវភេទស្របគ្នានឹងទណ្ឌកម្មចំពោះការរំលោភសេពសន្ថវៈ ។ ច្បាប់ចែងពីទណ្ឌកម្មចំពោះការជួញដូរដែលមានភាពតឹងតែងគ្រប់គ្រាន់ ។ នគរបាលកម្ពុជាបានស៊ើបអង្កេតករណីជួញដូរមនុស្សចំនួន ៤៩ ករណី ហើយដែលមានការពាក់ព័ន្ធជនល្មើសចំនួន ៦៥ នាក់ ដោយក្នុងនោះមាន ១០ ករណីត្រូវបានជំនុំជំរះទោសកាលពីឆ្នាំកន្លងទៅដោយមានការដាក់ពិន័យអោយជាប់ពន្ធនាគារពី ១ ឆ្នាំដល់ ១៨ ឆ្នាំ ។ ក្នុងឆ្នាំ ២០០៦ តុលាការក្រុងភ្នំពេញបានធ្វើការជំនុំជំរះលើករណីចំនួន ៣៧ ពាក់ព័ន្ធនឹងជនល្មើសចំនួន ៥៣ នាក់ ដែលជាប់ពន្ធនាគារពី ៥ ទៅ ២៤ ឆ្នាំ ។ អង្គការមិនមែនរដ្ឋាភិបាលមួយដែលធ្វើការប្រឆាំងនឹងការជួញដូរមនុស្ស បានរាយការណ៍ពីការចាប់ខ្លួនជនសង្ស័យ

ក្នុងការជួញដូរចំនួន ២១ នាក់ និងការកាត់ទោសជនប្រព្រឹត្តការជួញដូរចំនួន ២៨ នាក់ ក្នុងឆ្នាំ ២០០៦ ដោយមានការកំណត់ទោសជាប់ពន្ធនាគារពី ១ ឆ្នាំដល់ ១៩ ឆ្នាំ និងការសងប្រាក់ដល់ជនរងគ្រោះពី ៣ លាន ទៅ ១០ លានរៀន (ពី ៧៥០ ទៅ ២ ៥០០ ដុល្លាអាមេរិក) ។ ស្ថិតិទាំងនេះអាចមានការជាន់គ្នា ពីព្រោះនៅកម្ពុជា មិនមានប្រព័ន្ធ បូកសរុបទិន្នន័យដែលបានប្រមូលមកទេ ។ ក្នុងឆ្នាំនោះដែរ រដ្ឋាភិបាលបានកាត់ទោសមន្ត្រីនគរបាលមួយចំនួនទាក់ទងនឹងបទចោទប្រកាន់ថាបានជួញដូរមនុស្ស ។ អតីតអនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនត្រូវបានកាត់ទោស ចំពោះការពាក់ព័ន្ធក្នុងការជួញដូរមនុស្ស ហើយត្រូវបានដាក់អោយជាប់ពន្ធនាគារចំនួន ៥ ឆ្នាំ ។ មន្ត្រី ២ នាក់ក្រោមបង្គាប់ជននេះក៏ត្រូវបានអោយជាប់ពន្ធនាគារ ៧ ឆ្នាំផងដែរ ។ នគរបាលបានចាប់ខ្លួនមន្ត្រីតំរួតយោធាចំនួន ២ រូប និងសមាជិកបុគ្គលិកតំរួតយោធាមួយរូប ពីបទបើកបននិងជួញដូរមនុស្ស ។ ម្នាក់ត្រូវព្យួរទោសជាប់ពន្ធនាគារចំនួន ៥ ឆ្នាំនិងត្រូវបានពិន័យចំនួន៥ លានរៀល (១ ២៥០ ដុល្លាអាមេរិក) ។ នៅចុងឆ្នាំ ២០០៦ តុលាការឧទ្ធរណ៍បានដោះលែងម្ចាស់ផ្ទះបនដ៏ធំម្នាក់ ដែលត្រូវបានគេដឹងថាបាន ជួញដូរស្ត្រីនិងកុមារ ។ ផ្ទះបននោះបានបើកឡើងវិញដោយដាក់ឈ្មោះថ្មី ហើយនៅដើមឆ្នាំ ២០០៧ នគរបាលបាន ធ្វើការឆ្មក់ចូលហើយចាប់ម្ចាស់ផ្ទះបននោះឡើងវិញ ព្រមទាំងមនុស្ស ២ នាក់ទៀត ។ នាយករដ្ឋមន្ត្រីបានសុំអោយក្រុមប្រឹក្សាកំពូលនៃអង្គចៅក្រមធ្វើការស៊ើបអង្កេតការសំរេចរបស់តុលាការឧទ្ធរណ៍ ។ ស្វាយប៉ាកដែលជាតំបន់ផ្ទះបនដ៏ល្បីឈ្មោះនៅភ្នំពេញត្រូវបានបិទម្តង កាលពីឆ្នាំ ២០០៥ ដោយប្រតិបត្តិការរបស់នគរបាលប្រឆាំងការជួញដូរ តែបានបើកឡើងវិញនៅដើមឆ្នាំ ២០០៧ ។

**ទេសចរណ៍ផ្លូវភេទលើកុមារ**

ក្នុងឆ្នាំ ២០០៦ ទេសចរបរទេសដែលបានរួមភេទជាមួយកុមារត្រូវបានចាប់ខ្លួន ដោយនគរបាលកម្ពុជា ហើយបីនាក់ត្រូវបានជំនុំជំរះទោស ដោយត្រូវជាប់ពន្ធនាគារពី ១ ឆ្នាំដល់ ១៨ ឆ្នាំ ។ ជនជាតិអាមេរិកម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទរួមភេទជាមួយកុមារ ត្រូវបានដោះលែងនៅនៅក្រៅឃុំ នៅក្រុងព្រះសីហនុ ក្នុងលក្ខណៈដែលគួរអោយមានការសង្ស័យ ។ ប្រទេសកម្ពុជាបានបន្តជួយអាជ្ញាធរផ្នែកអនុវត្តច្បាប់របស់សហរដ្ឋអាមេរិក ក្នុងការចាប់បញ្ជូនទៅសហរដ្ឋអាមេរិកនូវជនជាតិអាមេរិកដែលបានធ្វើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។ ក្នុងឆ្នាំកន្លងទៅ កម្ពុជាបានសំរបសំរួលការចាប់បញ្ជូនចេញនូវជនជាតិអាមេរិកម្នាក់ ដែលត្រូវបានចោទប្រកាន់ពីការធ្វើទេសចរណ៍ផ្លូវភេទ ដើម្បីទទួលការកាត់ទោសនៅសហរដ្ឋអាមេរិក ក្រោមច្បាប់ PROTECT Act របស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ។ លើសពីនេះទៀត កម្ពុជាបានជួយក្នុងការបញ្ជូនចេញនូវជនជាតិអាមេរិកពីរនាក់ទៀត ដែលរងការចោទប្រកាន់របស់សហរដ្ឋអាមេរិកពីបទកេងប្រវ័ញ្ចផ្លូវភេទនិងផលិតរូបអាសអាភាកុមារ ។

**ការការពារ**

រដ្ឋាភិបាលកម្ពុជាបានបន្តផ្តល់ជំនួយដោយមានកំរិតព្រំដែនដល់ជនរងគ្រោះ ដោយពឹងផ្អែកលើអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការអន្តរជាតិចំពោះសេវាការពារភាគច្រើនសំរាប់ជនរងគ្រោះ ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន ស្តារយុវនិតិសម្បទារមានកន្លែងទទួលអោយស្នាក់នៅបណ្តោះអាសន្នចំនួនពីរកន្លែង ហើយធ្វើការសហការ

ជាមួយអង្គការមិនមែនរដ្ឋាភិបាល ក្នុងការជួយធ្វើសមាហរណកម្មដំបូងៗរបស់ជនរងគ្រោះ ។ នគរបាលបានលើកទឹកចិត្តអោយជនរងគ្រោះឆ្លើយជាកសិណ តែការភ័យខ្លាចការសងសឹករបស់ជនប្រព្រឹត្តការជួញដូរនៅតែរារាំងមិនអោយជនរងគ្រោះឬសាក្សីសហការជាមួយសមត្ថកិចដដែល្ល ។ ជនរងគ្រោះអាចធ្វើបណ្តឹងរដ្ឋប្បវេណីនិងប្តឹងផ្តល់តាមផ្លូវ ច្បាប់ប្រឆាំងជនប្រព្រឹត្តការជួញដូរ ។ សិទ្ធិរបស់ជនរងគ្រោះត្រូវបានគោរព ហើយពួកគេមិនត្រូវបានចាប់ខ្លួន ដាក់ ពន្ធនាគារ ផាកពិន័យ ឬចាប់បញ្ជូនចេញក្រៅប្រទេសទេ ។ មន្ត្រីអន្តោប្រវេសន៏និងមន្ត្រីផ្នែកពង្រឹងច្បាប់អនុវត្ត នីតិវិធីផ្លូវការ ដើម្បីរកមើលជនរងគ្រោះក្នុងចំណោមជនរងគ្រោះដែលងាយរងគ្រោះ ដូចជាកុមារីតាមផ្ទះបន ហើយបញ្ជូនពួកគេទៅមន្ទីរសង្គមកិច្ចខេត្ត ក្រុងដែលនៅទីនោះពួកគេត្រូវបានសំភាសន៏ហើយបញ្ជូនទៅកន្លែងទទួលអោយស្នាក់នៅរបស់អង្គការមិនមែនរដ្ឋាភិបាល សំរាប់រយៈពេលខ្លីឬវែង អាស្រ័យលើតំរូវការរបស់ពួកគេ ។ ក្នុងឆ្នាំ ២០០៦ ជនរងគ្រោះកម្ពុជាចំនួន ២៥២ នាក់ដែលត្រូវបានជួញដូរទៅប្រទេសថៃ ត្រូវបានបញ្ជូនមកមាតុភូមិវិញដោយរដ្ឋាភិបាលថៃ ក្រោមការសំរបសំរួលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង ស្តារនិតិសម្បទារ និងអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ។ ក្រសួងទេសចរណ៏បានបើកសិក្ខាសាលាសំរាប់បុគ្គលិកនិងម្ចាស់ក្រុមហ៊ុនក្នុងឧស្សាហកម្មទេចរណ៏ ស្តីពីវិធីរកមើលនិងធ្វើអន្តរាគមន៏ក្នុងករណីជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។

## ការបង្ការ

រដ្ឋាភិបាលកម្ពុជាត្រូវបានគេមើលឃើញថាមិនបានខិតខំច្រើនប៉ុន្មានទេ ដើម្បីរារាំងការជួញដូរមនុស្ស ។ អង្គភាពនគរបាលប្រឆាំងការជួញដូរមនុស្ស របស់ក្រសួងមហាផ្ទៃបានបើកយុទ្ធនាការអប់រំដល់កូនសិស្សសាលាអំពីគ្រោះថ្នាក់នៃការជួញដូរនិងសិទ្ធិរបស់គេ ។ ក្នុងឆ្នាំ ២០០៦ យុទ្ធនាការរបស់នគរបាលបានធ្វើដល់កូនសិស្សចំនួនប្រហែល ២០ ០០០ នាក់នៅខេត្តសៀមរាបនិង ៣ ០០០ នាក់នៅភ្នំពេញ ។ ដោយធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការអន្តរជាតិ រដ្ឋាភិបាលបានបើកយុទ្ធនាការលើកកំពស់ការយល់ដឹងរបស់សាធារណៈជននៅទូទាំងប្រទេស ដោយប្រើផ្ទាំងរូបភាព ទូរទស្សន៏ វិទ្យុ និងល្ខោនប្រពៃណីខ្មែរ ។ ប្រទេសកម្ពុជាមិនបានធ្វើសច្ចានុម័តលើពិធីសារឆ្នាំ ២០០០ របស់សហប្រជាជាតិស្តីពីការជួញដូរមនុស្សទេ ។